# រាជបណ្ឌិត្យសភាកម្ពុជា

## លទ្ធផលកិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ
## នៃក្រុមប្រឹក្សាជាតិភាសាខ្មែរ នៅខែកុម្ភៈ ឆ្នាំ២០១៨

( ចងក្រងដោយ៖ RAC Media; ប្រភពឯកសារ៖ កជភខ )

### ១-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៨

ថ្ងៃអង្គារ ៦រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ជួរ គារី បានបន្តប្រជុំពិនិត្យ និងអនុម័តបច្ចេកសព្ទគណៈកម្មការទស្សនវិជ្ជាបានចំនួន០៣ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១. អភិទស្សនវិជ្ជា<br>អ. Metaphilosophy<br>បារ. métaphilosophie | ទស្សនវិជ្ជាដែលសិក្សាអំពីទស្សនវិជ្ជាខ្លួនឯង ពោលគឺសិក្សាពីធម្មជាតិ វិធី គោលបំណង ស្វ័យភាព សត្យានុមតភាព និងសំណួររបស់ទស្សនវិជ្ជា ព្រមទាំងទំនាក់ទំនងរវាងទស្សនវិជ្ជានិងមុខវិជ្ជាដទៃទៀត។<br>អភិទស្សនវិជ្ជាជាបច្ចេកសព្ទមួយបង្ហាញដោយទស្សនវិទូ ឡាសេរ៉ូវីត (Lazerowitz ១៩០៧-១៩៨៧) ជនជាតិប៉ូឡូញ សញ្ជាតិអាមេរិក។ |
| ២. បុព្វវាសនា<br>អ. Predestination<br>បារ. Prédestination | សាសនវិជ្ជាដែលអះអាងថា ព្រឹត្តិការណ៍ទាំងអស់នៅក្នុងដំណើរជីវិតរបស់មនុស្សម្នាក់ៗ ពោលគឺអ្វីៗដែលបានកើតឡើង កំពុងកើតឡើង ឬនឹងកើតឡើង ត្រូវបានកំណត់ជាមុនដោយអាទិទេពនិងមិនអាចកែប្រែបាន។ ការកំណត់ថាតើព្រលឹងរបស់មនុស្សម្នាក់ៗនឹងឡើងទៅឋានសួគ៌ឬធ្លាក់ទៅឋាននរក ត្រូវបានសម្រេចដោយឆន្ទៈរបស់អាទិទេពតាំងពីមនុស្សនោះកើតមកម្ល៉េះ ដោយមិនអាស្រ័យលើការប្រព្រឹត្តរបស់គេឡើយ។<br>(ពាក្យនេះគេប្រើនៅក្នុងទស្សនវិជ្ជាអំពីសាសនា អភិរូបវិជ្ជា និងតក្កវិជ្ជា)។ |

| | |
|---|---|
| ៣. សីលវិជ្ជាជីវៈ<br>អ. Bioethics<br>បា. Bioéthique | មែកធាងមួយនៃសីលវិជ្ជាអនុវត្តដែលទាក់ទងនឹងបញ្ហាសីលធម៌ស្ដីពីជីវិតនិងមរណភាព ដែលផ្ដើមចេញពីការស្រាវជ្រាវខាងជីវសាស្ត្រនិងវេជ្ជសាស្ត្រទំនើបនិងការប្រតិបត្តិក្នុងការថែទាំសុខភាព។<br>សីលវិជ្ជាជីវៈជាក្រមសីលធម៌នៃជីវិតតម្រូវឱ្យអ្នកស្រាវជ្រាវខាងជីវវិទ្យា វេជ្ជសាស្ត្រ ឱសថសាស្ត្រ បសុសាស្ត្រ គីមីសាស្ត្រ បរិស្ថានវិទ្យា និងបច្ចេកវិទ្យាផ្សេងៗប្រតិបត្តិតាម ហើយវាក៏ជានិយាមសីលធម៌មួយប្រើសម្រាប់វាស់អំពើរបស់អ្នកសិក្សាស្រាវជ្រាវក្នុងវិស័យខាងលើឱ្យដឹងថាតើពួកគេប្រតិបត្តិតាមគោលការណ៍សីលវិជ្ជាជីវៈបានកម្រិតណា។<br>បញ្ហាដែលពាក់ព័ន្ធនឹងសីលវិជ្ជាជីវៈ ដូចជា ការផ្ដល់ធនធានវេជ្ជសាស្ត្រកម្រកម្រិតស្វ័យភាពរបស់អ្នកជំងឺព្រមទាំងវិសាលភាពនិងព្រំដែននៃអំណាចរបស់វេជ្ជបណ្ឌិតនិងគិលានុបដ្ឋាក ការរំលូតកូននិងសុឃាត ការធ្វើពិសោធន៍លើមនុស្ស ការស្រាវជ្រាវពន្ធុ (ហ្សែន) ការពន្យារកំណើត បច្ចេកទេសក្នុងការបង្កកំណើតមនុស្ស ការពិនិត្យគភ៌ ការពពោះជំនួស ការបរិច្ចាគជាលិកាឬសរីរាង្គជាដើម។ |

## ២-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៨

ថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ហ៊ាន សុខុម ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ បានបន្តប្រជុំពិនិត្យនិងអនុម័តបច្ចេកសព្ទគណៈកម្មការសុខាភិបាលបានចំនួន០៧ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- អាក់ទីណូព្យាបាល<br>អ. actinotherapy<br>បារ. actinothérapie (f.) | វិធីព្យាបាលជំងឺដោយប្រើកាំរស្មីស្វាយអ៊ុលត្រា(ultraviolet) កាំរស្មីក្រហមអាំងហ្វ្រា (infrarouge)...។ |
| ២- អាក់ទីវ៉ាទ័រ<br>អ. activator<br>បារ. activateur(m.) | វត្ថុធាតុរូបឬគីមី(élément physique ou chimique) ដែលជួយពន្លឿនជីវប្រតិកម្ម(réaction biologique)។ |
| ៣- អាក់ទីវ៉ាស្យុង<br>អ. activation<br>បារ. activation(f.) | ការពន្លឿនជីវប្រតិកម្មដោយប្រើអាក់ទីវ៉ាទ័រ។ |
| ៤- អាគ្វីតេ<br>អ. acuteness/ acuity<br>បារ. acuité(f.) | សមត្ថភាពនៃវិញ្ញាណដែលអាចវិនិច្ឆ័យអ្វីៗដែលតូចឬតិចបំផុត។ |
| ៥- អាគ្វីតេល្ឺ<br>អ. auditory acuity<br>បារ. acuité auditive(f.) | សមត្ថភាពនៃសោតវិញ្ញាណដែលអាចទទួលសំឡេងតិចបំផុតបាន។ |
| ៦- អាគ្វីតេគំហើញ<br>អ. visual acuity<br>បារ. acuité visuelle(f.) | សមត្ថភាពនៃចក្ខុវិញ្ញាណដែលអាចមើលឃើញរូបភាពតូចបំផុតបាន។ |
| ៧- ស្រួចស្រាល់កម្ម/ ស្រួចស្រាល់នីយកម្ម<br>អ. acutization<br>បារ. acutisation(f.) | ការវិវត្តជំងឺពីរ៉ាំរ៉ៃទៅស្រួចស្រាល់។ |

## ៣-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨

ថ្ងៃអង្គារ ១៣រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ជួរ គារី បានបន្តប្រជុំពិនិត្យ និងអនុម័តបច្ចេកសព្ទគណៈកម្មការទស្សនវិជ្ជាបានចំនួន០៣ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- អនុមាន<br>អ. inference<br>បារ. inférence (f.) | វិធីនៃការទាញសេចក្តីសន្និដ្ឋានដែលមានតម្លៃខាងតក្កវិជ្ជាពិតឬមិនពិតចេញពីសេចក្តីថ្លែង/អំណះអំណាងមួយឬច្រើន។<br>ជាទូទៅអនុមានចែកចេញជាអនុមានរួម(Induction)និងអនុមានញែក(Deduction)។ ក្នុងករណីខ្លះ គេរាប់បញ្ចូលវិសេសានុមាន(Abduction) ជាប្រភេទទីបីនៃអនុមានដែរ ប៉ុន្តែជាញឹកញាប់គេចាត់ទុកវាថាជាករណី វិសេសនៃអនុមានរួម។<br>(ពាក្យនេះគេប្រើនៅក្នុងតក្កវិជ្ជា) |
| ២- អនុមានរួម<br>អ. induction<br>បារ. induction(f.) | វិធីនៃការពិចារណាដែលទាញសេចក្តីសន្និដ្ឋានចេញពីសច្ចភាពឬករណីដោយឡែកៗទៅរកសច្ចភាពសាកលឬការធ្វើទូទៅនីយកម្មលើមូលដ្ឋាននៃសច្ចភាពឬក៏ករណីដោយឡែកៗមួយចំនួនផ្អែកលើតក្កសាស្ត្រ។<br>សេចក្តីសន្និដ្ឋានរបស់អនុមានរួម ជាទូទៅមានសភាពប្រហែលជាជាងសភាពពិតដាច់ខាត។<br>ឧទាហរណ៍៖<br>- ដែកចម្លងអគ្គិសនី ទង់ដែងចម្លងអគ្គិសនី ប្រាក់ចម្លងអគ្គិសនី។<br>- ដែក ទង់ដែង ប្រាក់ ជាលោហៈ។<br>ដូច្នេះ លោហៈទាំងអស់ចម្លងអគ្គិសនី។<br>(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា) |
| ៣- អនុមានញែក<br>អ. deduction<br>បារ. déduction(f.) | វិធីនៃការពិចារណាដែលទាញសេចក្តីសន្និដ្ឋានពីសច្ចភាពសាកលទៅរកសច្ចភាពដោយឡែកៗ ដោយផ្អែកលើតក្កសាស្ត្រ។<br>សេចក្តីសន្និដ្ឋានរបស់អនុមានញែក មានសភាពពិតដាច់ខាត។<br>ឧទាហរណ៍៖<br>- មនុស្សទាំងអស់ ជាយថាហេតុនឹងស្លាប់។<br>- សុខ ជាមនុស្ស។<br>- ដូច្នេះ សុខ ជាយថាហេតុនឹងស្លាប់ដែរ។<br>(ពាក្យនេះ គេប្រើនៅក្នុងតក្កវិជ្ជា) |

## ៤-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨

ថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត ជួរ គារី បានបន្តប្រជុំពិនិត្យ និងអនុម័តបច្ចេកសព្ទគណៈកម្មការទស្សនវិជ្ជាបានចំនួន២ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ៦៩- វិធីសូន្យ<br>អ. zero method<br>បារ. Méthode zéro | វិធីមួយដែលបង្ហាញយ៉ាងច្បាស់អំពីទម្រង់មូលដ្ឋាននៃភាសា ដោយ ការបង្កើតពាក្យមួយតាមរយៈបន្សំនៃសញ្ញានានា។ ដោយសារតែទម្រង់តែមួយគត់របស់វា សញ្ញាទាំងនេះបានលុបចោលទាំងស្រុងនូវខ្លឹមសាររូបធាតុរបស់ខ្លួន។ វិធីសូន្យ គឺជាវិធីតក្កវិជ្ជាស្តីពីការបង្កើតគំរូមួយផ្អែកលើការសន្មតទៅតាមសនិទានភាព។<br>ឧទាហរណ៍៖ ក្នុងវិធីសូន្យ គេបង្កើតពាក្យ «ត្រី» (បញ្ញត្តិត្រី) ពីទម្រង់ឬរូបរាងផ្សេងៗរបស់សត្វត្រីជាក់ស្តែង។<br>(ពាក្យនេះគេប្រើក្នុងតក្កវិជ្ជា និងទស្សនវិជ្ជាអំពីភាសា) |
| ៧០- តម្លៃសច្ចភាព<br>អ.truth-value<br>បារ. valeur de vérité | ភាពពិតឬភាពមិនពិតដែលមាននៅក្នុងសេចក្តីថ្លែងនីមួយៗ។<br>តក្កវិជ្ជាបុរាណអះអាងថា រាល់សេចក្តីថ្លែងត្រូវតែពិតឬមិនពិត ហើយភាពពិតឬភាពមិនពិតរបស់វា គឺជាតម្លៃសច្ចភាពរបស់វា។ ប្រសិនបើសេចក្តីថ្លែងនោះពិត តម្លៃសច្ចភាពរបស់វាគឺភាពពិត ប្រសិនបើសេចក្តីថ្លែងនោះមិនពិត តម្លៃសច្ចភាពរបស់វាគឺភាពមិនពិត។<br>«ធ្យូងថ្មនោះមានពណ៌ស» មិនពិត, ដូច្នេះ យើងនិយាយថា តម្លៃសច្ចភាពនៃប្រយោគនោះគឺភាពមិនពិត។ «ទឹកកកសុទ្ធមានពណ៌ស» ពិត ដូច្នេះ យើងនិយាយថា តម្លៃសច្ចភាពនៃប្រយោគនោះគឺភាពពិត។ ប្រសិនបើសេចក្តីថ្លែងពីរដូចគ្នា វាមានតម្លៃសច្ចភាពដូចគ្នា។ គោលការណ៍ស្តីពីទ្វិកលក្ខណៈនៅក្នុងតក្កវិជ្ជាបុរាណទទួលស្គាល់តម្លៃសច្ចភាពតែពីរ ចំណែកឯ ទម្រង់មួយចំនួននៃតក្កវិជ្ជាទំនើប បដិសេធការសន្មតនេះ ហើយអះអាងថាតក្កវិជ្ជាមានតម្លៃបីឬច្រើន។ លោក ស្រ្តូ សាន់ (Strawson) អះអាងថា អាចមានសេចក្តីថ្លែងដែលគ្មានតម្លៃសច្ចភាព ពោលគឺ សេចក្តីថ្លែងដែលមិនពិត ហើយក៏មិនខុសដែរ និង ដែលមានចន្លោះតម្លៃសច្ចភាព។<br>(ពាក្យនេះគេប្រើនៅក្នុងតក្កវិជ្ជា) |

## ៥-កិច្ចប្រជុំគណៈកម្មការបច្ចេកសព្ទ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨

ថ្ងៃពុធ ១៤កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត ជួរ គារី បានប្រជុំពិនិត្យ ពិភាក្សា និងអនុម័តបច្ចេកសព្ទគណៈកម្មការវិទ្យាសាស្ត្រសេដ្ឋកិច្ច បានចំនួន ០៦ពាក្យ ដូចខាងក្រោម៖

| | |
|---|---|
| ១- មូលធននិយម<br>អ. capitalism<br>បារ. capitalisme (m.) | ប្រព័ន្ធសេដ្ឋកិច្ចមួយដែលនៅក្នុងនោះ មធ្យោបាយផលិតកម្មជាកម្មសិទ្ធិរបស់ម្ចាស់ទុនឯកជនដែលធ្វើប្រតិបត្តិការដើម្បីស្វែងរកប្រាក់ចំណេញ។ |
| ២- ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.)<br>អ. gross domestic product (GDP)<br>បារ. produit intérieur brut (PIB) | តម្លៃសរុបនៃទំនិញនិងសេវាដែលបានផលិតដោយប្រជាជនក្នុងប្រទេសណាមួយក្នុងរយៈពេលមួយឆ្នាំ ដោយមិនរាប់បញ្ចូលតម្លៃនៃប្រាក់ចំណូលបានពីបរទេសទេ។ |
| ៣- ផលិតផលជាតិសរុប (ផ.ជ.ស.)<br>អ. gross national product (GNP)<br>បារ. produit national brut (PNB) | តម្លៃសរុបនៃទំនិញនិងសេវាដែលបានផលិតដោយប្រជាជននៃប្រទេសណាមួយក្នុងរយៈពេលមួយឆ្នាំ។ |

| | |
|---|---|
| ៤- ម៉ាក្រូសេដ្ឋកិច្ច<br>អ. macroeconomics<br>បារ. macroéconomie (f.) | ផ្នែកមួយនៃវិទ្យាសាស្ត្រសេដ្ឋកិច្ចសិក្សាអំពីប្រព័ន្ធសេដ្ឋកិច្ចជាតិទាំង មូល ដែលផ្តោតទៅលើចំណូលជាតិ កំណើនសេដ្ឋកិច្ច និកម្មភាព អតិផរណាជាដើម។ |
| ៥- មីក្រូសេដ្ឋកិច្ច<br>អ. microeconomics<br>បារ. microéconomie (f.) | ផ្នែកមួយនៃវិទ្យាសាស្ត្រសេដ្ឋកិច្ចសិក្សាអំពីឥរិយាបថរបស់បុគ្គល ក្រុមហ៊ុន ឬស្ថាប័នដែលពាក់ព័ន្ធទៅនឹងជម្រើសនិងការសម្រេចចិត្តក្នុងការឆ្លើយតបនឹងថ្លៃទំនិញនិងតម្រូវការក្នុងទីផ្សារ។ |
| ៦- ផែនការអាជីវកម្ម<br>/ផែនការធុរកិច្ច<br>អ. business plan<br>បារ. projet commercial(m.) | ឯកសារជាលាយលក្ខណ៍អក្សរពិពណ៌នាអំពីជំហានចាំបាច់ទាំងអស់ដើម្បីចាប់ ផ្តើមនិងប្រតិបត្តិការអាជីវកម្មឱ្យបានជោគជ័យ។<br>ចំណុចសំខាន់ៗនៃផែនការអាជីវកម្មមានដូចជា គោលបំណង គោលដៅ សកម្មភាពធនធានមនុស្ស ថវិកាដែលត្រូវចំណាយជាដើម។ |